# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

លេខ: 31 PR-17/EoJ ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧

## ការប្រលងជ្រើសរើសបេក្ខជនចូលរួមកម្មវិធីផ្លាស់ប្តូរយុវជនJENESYS2017 ទៅប្រទេសជប៉ុន

ស្ថានទូតជប៉ុន មានសេចក្តីសោមនស្សរីករាយជម្រាបជូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិមេត្តាជ្រាបថា: ការប្រលងជ្រើសរើសបេក្ខជនចូលរួមកម្មវិធីផ្លាស់ប្តូរយុវជនJENESYS2017 រឺហៅថា (កម្មវិធីបណ្តាញផ្លាស់ប្តូរសិស្ស និស្សិត និងយុវជន រវាងប្រទេសជប៉ុន និងបណ្តាប្រទេសអាស៊ីខាងកើត) ត្រូវបានប្រព្រឹត្តទៅដោយជោគជ័យនាថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន។

កម្មវិធី JENESYS គឺជាកម្មវិធីផ្លាស់ប្តូរយុវជនដែលរៀបចំឡើងដោយក្រសួងការបរទេសជប៉ុន ដើម្បីជម្រុញការយល់ដឹង និងកសាងទំនុកចិត្តគ្នាទៅវិញទៅមកក្នុងចំណោមប្រជាជនជប៉ុន និងបណ្តាប្រទេស ចូលរួម និងដើម្បីកសាងមូលដ្ឋានគ្រឹះនៃកិច្ចសហប្រតិបត្តិការ និងចំណងមិត្តភាពនាពេលអនាគត។

ការប្រលងជ្រើសរើសនេះ រៀបចំដោយស្ថានទូតជប៉ុនប្រចាំនៅកម្ពុជា សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន។ និស្សិតចំនួន៤៨រូប ក្នុងចំណោម ១២ក្រុម ដែលត្រូវបានជ្រើសរើសពីវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ បានឡើងធ្វើបទបង្ហាញក្រោមប្រធានបទ « ប្រទេសកម្ពុជាដ៏អស្ចារ្យរបស់ខ្ញុំ»ដោយផ្អែកលើភាពច្នៃប្រឌិត ភាពទាក់ទាញ និងសាមគ្គីភាព។

និស្សិត៦ក្រុម ដែលមាន២៤រូបត្រូវបានជ្រើសរើសសម្រាប់វគ្គផ្តាច់ព្រ័ត្រនេះ (សូមមើលតារាងភ្ជាប់នៅខាងក្រោម) នឹងត្រូវអញ្ជើញទៅប្រទេសជប៉ុនចាប់ពីថ្ងៃ១៥ ដល់ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ ក្រោមកម្មវិធីផ្លាស់ប្តូរយុវជនJENESYS2017 ដែលផ្តល់ដោយរដ្ឋាភិបាលជប៉ុន។

កម្មវិធីនេះនឹងជម្រុញឲ្យអ្នកចូលរួមមានឱកាសបានយល់ដឹងកាន់តែស៊ីជម្រៅពីប្រទេសជប៉ុន ព្រមទាំងបានចែករំលែកនូវបទពិសោធន៍របស់ខ្លួនបានទូលំទូលាយទៅកាន់ប្រជាជនកម្ពុជា ក្រោយពីការវិលត្រលប់មកកាន់មាតុភូមិវិញ។

តារាងឈ្មោះបេក្ខជនជ័យលាភីទាំង២៤រូបក្នុងចំណោម៦ក្រុម៖

| No. | Name of Students | Sex | Name of Universities | Title of presentation |
|---|---|---|---|---|
| 1 | Leak Sophavatey | F | American University of Phnom Penh | Smile as a way to say hello |
| | Chin Chanda Luch | F | | |
| | Prom Sophamonyoudom | M | | |
| | Heng Leaksmy | F | | |
| 2 | Kong Sethapisey | F | Royal University of Fine Arts | Kbach Angkor |
| | Heng Seila | M | | |
| | Theuon Socheat | M | | |
| | Phor Phann | M | | |
| 3 | Nat Odom | M | Royal University of Law and Economics | Traditional Clothes |
| | Soeurnsayorn Thakvika | M | | |
| | Oeng Guechly | F | | |
| | Chou Ratha | F | | |
| 4 | Vann Chansopheak Vatey | F | Royal University of Phnom Penh | Palm Tree |
| | Bun Saosopheakneath | F | | |
| | Hing Socheata | F | | |
| | Seng Solydeth | F | | |
| 5 | Uch Daneth | F | Zaman University | Lakhaon Khaol, Cambodian Mask Dance |
| | Lim Farrorza | M | | |
| | Hong Channarong | M | | |
| | Chheng Seang Hay | M | | |
| 6 | Se Sokunvathna | M | Zaman University, American University of Phnom Penh | Khmer Kite(Khleng EK) |
| | Kong Watanakbotra | M | | |
| | Nuon Kanika | F | | |
| | Punlork Sithearith | M | | |



រូបថតក្រុមជ័យលាភីជាមួយគណៈកម្មការ